**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ.....៣៦៦.......បទ. ឋ.ម..............

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសនិស្សិតនិងមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារ ក្នុងក្របខ័ណ្ឌក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សម្រាប់ឆ្នាំ២០១៩

**យោង៖** លិខិតលេខ ១០៩៧ មស.ក្រខ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជូនដំណឹងដល់និស្សិតនិងមន្ត្រីរាជការស៊ីវិលទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសនិស្សិតនិងមន្ត្រីរាជការស៊ីវិលដែលមានសញ្ញាបត្របរិញ្ញាបត្រឡើង ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់ឆ្នាំ២០១៩ ចំនួន ៣០កន្លែង (ក្របខ័ណ្ឌ «ក») តាមលក្ខខណ្ឌដូចខាងក្រោម៖

### ក. លក្ខខណ្ឌជ្រើសរើស

**១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ**

**២. លក្ខខណ្ឌអាយុ (គិតត្រឹមថ្ងៃប្រឡង)៖**

- បេក្ខជនដែលមានសញ្ញាបត្រចាប់ពីថ្នាក់បណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត៤០ឆ្នាំ
- បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត៣៥ឆ្នាំ។

**៣. កម្រិតសញ្ញាបត្រ៖**

- ចំពោះសញ្ញាបត្រសិក្សាជាភាសាបរទេសត្រូវធ្វើការបញ្ជាក់ជាភាសាជាតិ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា (ក្នុងករណីការបញ្ជាក់ទទួលស្គាល់មានការយឺតយ៉ាវ បេក្ខជនអាចភ្ជាប់បង្កាន់ដៃបញ្ជាក់ឯកសារសញ្ញាបត្រនៅក្រសួងអប់រំ យុវជន និងកីឡា ជាបណ្តោះអាសន្ន)
- ករណីរកឃើញមានការក្លែងបន្លំសញ្ញាបត្រឬលិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញដោយស្វ័យប្រវត្តិ។

**៤. ចំពោះបេក្ខជនជាមន្ត្រីរាជការ**

ត្រូវបានលើកលែងលក្ខខណ្ឌអាយុ តែត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមការប្រឡងប្រជែងពីប្រធានស្ថាប័នសាមី។ ក្រោយពេលប្រឡងជាប់ជាស្ថាពរ បេក្ខជនត្រូវរៀបចំផ្ទេរក្របខ័ណ្ឌទៅអង្គភាពថ្មី ដោយត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងឡើយ។

**៥. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ**

**៦. បេក្ខជនជា ជនពិការ ស្ត្រី និងជនជាតិដើមភាគតិច ដែលមានសមត្ថភាពសមស្រប ត្រូវបានផ្តល់អាទិភាព**

### ខ. សំណុំលិខិតចុះឈ្មោះសុំសិទ្ធិប្រឡង៖

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ០១ ច្បាប់ |
| ២. ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី (៤ x ៦) | ០១ ច្បាប់ |
| ៣. សាលាកបត្រឯកត្តជន | ០១ ច្បាប់ |
| ៤. បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង | ០១ ច្បាប់ |
| ៥. កិច្ចសន្យាការងារ | ០១ ច្បាប់ |

៦. សេចក្តីចម្លងសញ្ញាបត្រ..........................................................................................០១ ច្បាប់
៧. សេចក្តីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ.......................................០១ ច្បាប់
៨. សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ...........................................................០១ ច្បាប់
៩. លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់)...................................................................០១ ច្បាប់
១០. លិខិតពិនិត្យកាយសម្បទា (ក្រោយពេលប្រឡងជាប់)........................................................០១ ច្បាប់
១១. លិខិតអនុញ្ញាតរបស់ប្រធានស្ថាប័ន (សម្រាប់បេក្ខជនជាមន្ត្រីរាជការ)..................................០១ ច្បាប់

- **បញ្ជាក់៖** រាល់លិខិតស្នាមពាក់ព័ន្ធ ត្រូវមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ ហើយបេក្ខជនត្រូវមកដាក់ពាក្យសុំប្រឡងដោយផ្ទាល់ (មិនអនុញ្ញាតឱ្យមានអ្នកដាក់ពាក្យជំនួស)។

## គ. កាលបរិច្ឆេទ និងទីកន្លែងចុះឈ្មោះនិងទទួលពាក្យប្រឡង

- បេក្ខជនត្រូវបំពេញព័ត៌មានសុំសិទ្ធិប្រឡងតាមប្រព័ន្ធចុះឈ្មោះប្រឡងរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយចូលតាមគេហទំព័ររបស់ក្រសួងដែលមានអាសយដ្ឋាន៖ www.mptc.gov.kh ឬតាមរយៈតំណភ្ជាប់ (Link)៖ reg.mptc.gov.kh។
- បន្ទាប់ពីគណៈកម្មការរៀបចំការប្រឡង ពិនិត្យហើយបញ្ជាក់ថាព័ត៌មានសុំសិទ្ធិប្រឡងរបស់បេក្ខជនត្រឹមត្រូវ គណៈកម្មការនឹងជូនដំណឹងដល់បេក្ខជន រួចបេក្ខជនត្រូវធ្វើការបោះពុម្ពព័ត៌មានដែលបានបំពេញ ដោយភ្ជាប់មកនូវសំណុំលិខិតដូចមានក្នុងចំណុច "ខ" មកដាក់ពាក្យនិងបង់ថវិកាសុំសិទ្ធិប្រឡង (តម្លៃបីម៉ឺនរៀល) នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលមានអាសយដ្ឋាន អាគារលេខ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាវេលាម៉ោង១៧៖០០នាទី។

## ឃ. វិញ្ញាសាប្រឡង

- **វិញ្ញាសាសរសេរតាមប្រព័ន្ធកុំព្យូទ័រ** មាន៖
  - ចំណេះដឹងទូទៅ
  - ភាសាអង់គ្លេស
  - ព័ត៌មានវិទ្យា
- **វិញ្ញាសាសួរផ្ទាល់មាត់៖** សម្រាប់បេក្ខជនដែលប្រឡងជាប់វិញ្ញាសាសរសេរ។

## ង. កាលបរិច្ឆេទប្រឡងនិងមណ្ឌលប្រឡង

គណៈកម្មការរៀបចំការប្រឡងនឹងជូនដំណឹងអំពីកាលបរិច្ឆេទនិងមណ្ឌលប្រឡងនៅពេលក្រោយ។

- **សម្រាប់ព័ត៌មានលម្អិត៖** បេក្ខជនអាចសាកសួរដោយផ្ទាល់ (រៀងរាល់ម៉ោងធ្វើការ)
  - នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬតាមរយៈទូរស័ព្ទលេខ ០២៣ ២៣០ ០០០
  - សារអេឡិចត្រូនិក៖ info@mptc.gov.kh ឬហ្វេសប៊ុក http://www.facebook.com/officialmptc

**បញ្ជាក់៖** គណៈកម្មការរៀបចំការប្រឡងសូមរក្សាសិទ្ធិក្នុងការកែប្រែសេចក្តីជូនដំណឹងនេះក្នុងករណីចាំបាច់។

ថ្ងៃ ច័ន្ទ ១កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៩
**រដ្ឋមន្ត្រី**

ត្រាំ អ៊ីវតឹក

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  *"ដើម្បីជូនជ្រាប"*
- គ្រប់អង្គភាពក្រោមឱវាទក្រសួង ប.ទ
  *"ដើម្បីអនុវត្តនិងជួយផ្សព្វផ្សាយបន្ត"*
- ឯកសារ-កាលប្បវត្តិ